# ជីវិតឥតម៉ែ

(បទពាក្យ៨)

ដាក់ក្បាលដល់ខ្នើយគេងកើយហើយគិត
អាសូរជីវិតរសាត់តាមខ្យល់
សន្ទុះកម្មព្រេងបន្លែងអោយខ្វល់
រសាប់រសល់អំពល់ឥតល្ហែ។

យប់ថ្ងៃកន្លងឆ្លងជាអតីត
បន្សល់រឿងពិតជីវិតឥតម៉ែ
ស្រមោលក្ដីទុក្ខតាមលងដង្ហែ
ធ្មេចភ្នែកឃើញតែបុព្វអប្រិយ។

រលកសមុទ្រខ្ទប់ផ្ទាំងថ្មដា
រលកវាសនាបោកខ្ទប់លោកីយ៍
អោយកាយណាយគាប់អភ័ព្វរីងរៃ
ដូចកូនបក្សីព្រាត់ចាកសំបុក។

មើលទៅអ្នកផងគេសែនស្រស់ស្រាយ
មូលមីរសប្បាយជុំម្ដាយឪពុក
ជីវិតកក់ក្ដៅនៅគ្មានព្រួយទុក្ខ
ញញឹមពេញមុខសុខពេញឱរា។

យប់ថ្ងៃស្ដាប់សៀងសំនៀងពីរោះ
ផ្អែមល្ហែមឥតមោះចាកឱស្ឋមាតា
លួងលោមបំពេរមិនឱ្យឯកា
មានហត្ថទ្វេហាត្រកងថ្នមថ្នាក់។

អនិច្ចាឱកាយឆ្ងាយណាស់ក្ដីសុខ
រស់នៅក្នុងថ្លុកភក់កម្មអបល័ក្ខណ៍
សំលេងជេរស្ដីរំពាត់ផ្ដៅល្ពាក់
ជាគ្រឿងថ្នមថ្នាក់បង្ហួតលោកីយ៍។

ទឹកភ្នែកជោកថ្ពាល់បន្ទាល់ឈឺផ្សា
តំណក់ស ថ្លាជំនួសសំដី
ស្រែកថ្ងូររកម្ដាយ ៗកាន់ភពថ្មី
កូនដូចរាត្រីបាត់ព្រះចន្ទ្រា។

កាយញ័រចំប្រប់ព្រោះខ្លាចអាជ្ញា
ព្រឺព្រួយចិន្ដារង្គួយរងា
យកគេធ្វើម៉ែគេបែរផ្គន្ទា
ប៉ុនប៉ងចងពៀរគ្មានក្ដីមេត្តា។

វិលវល់វិយោគសោយសោកចំបែង
ជីវិតដូចផ្សែងហោះតាមវាតា
រសាត់អណ្ដែតតាមកម្មវាសនា
ផ្ញើរូបកាយាលើលោកធំធេង។

មានទឹកនេត្រាជាមិត្តរួមទុក្ខ
អារម្មណ៍ក្ដួលក្ដុកជាខ្នើយកើយគេង
សភាពឯកោគំរាមគ្រេងៗ
មេឃាធំធេងជាភួយដណ្ដប់។

សំនៀងភ្លៀងផ្គរបន្ទរយំស្រែក
សំលេងខ្លងខែកឱ្យទ្រូងចំប្រប់
ពេលនឹកអ្នកម៉ែផ្សងឱ្យយល់សប្ដិ៍
អនិច្ចាត្រូវកប់ក្នុងភាពសូន្យធេង។

ណ្ហើយ! ទ្រាំចុះណា៎កុមារអភ័ព្វ តស៊ូក្រែងគាប់ផុតសោកសង្រេង
ព្រលឹងម្ដាយអ្នកបំពេរអោយគេង ភ្ញាក់ឡើងស្ដាប់ភ្លេងទំនុកបទថ្មី។
ឱះឱ! មនុស្សលោកមានចិត្តខ្ពង់ខ្ពស់ ប្រោសអនុគ្រោះសន្ដោសប្រណី
កុំប្រើហិង្សាចិន្ដាអប្រិយ អោយក្មេងប្រុសស្រីរងកម្មវេរា។
បើគ្នាពឹងពាក់ផ្ញើកាយជ្រកកោន មេត្តាអត់ឱនទោះខុសទោះជា
ចិញ្ចឹមបីបាច់អប់រំការពារ ជាតិមនុស្សដូចគ្នាគួរចេះអាសូរ។
គិតថាជួយយកតែបុណ្យទៅចុះ កុំចាប់កំហុសដោយចិត្តទ្រឹស្ដិស្ទូរ
សូមកាន់ចិត្តធីមបវរផង់ផូរ អោយបានសំបូរនៅក្នុងចិន្ដា។
កុំយកចិត្តមារធ្វើជាប្រមុខ កុំសាងតែទុក្ខអោយស្ដុកកាយា
ឃើញសត្វធ្លាក់ទឹកជួយយកអាសា អោយមានវាសនាយល់រស្មីផង។

*(០២ មករា ២០០២)*

*ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម*